**ប្រជុំលើកទី១ (៩ កក្កដា ២០២៤)**

**<u>ប្រធានបទ/ពាក្យស្លោក</u>**

- ការអប់រំសីលធម៌ (ក្រសួងធម្មការនិងសាសនា)
- ការអប់រំល្អ គឺជាតម្លៃរបស់មនុស្ស (ក្រសួងធម្មការ)
- សុខដុមនីយកម្មសាសនា រួមគ្នាប្រឆាំងការអូសទាញ និងប្រឆាំងអំពើជួញដូរមនុស្សក្នុងសម័យឌីជីថល (ក្រសួងព័ត៌មាន)
- លើកកម្ពស់សុចរិតភាព វិទ្យាសាស្ត្របច្ចេកវិទ្យា ក្នុងសម័យឌីជីថល (ក្រសួងព័ត៌មាន)
- ការលើកកម្ពស់ការចូលរួមរបស់យុវជនប្រឆាំងការជួញដូរមនុស្ស ក្នុងសម័យឌីជីថល (វិទ្យុជាតិ)
- វិទ្យាសាស្ត្រខ្វះសីលធម៌ បំផ្លាញមនុស្សជាតិ (គ.ជ.ប.ជ)
- លើកកម្ពស់សីលធម៌សង្គម ជាវិធានការអប់រំដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
- ពណ៌សង្គម មនុស្សជាតិ (សមាគមសហគ្រិនស្ត្រី)
- ការជួញដូរមនុស្ស គឺជាអំពើបាប! (ព្រះសង្ឃ)
- រួមគ្នាប្រយុទ្ធប្រឆាំង/បង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស (ព្រះសង្ឃ)
- ខុសមួយជំហ៊ាន ខុសមួយជីវិត (សមាគមសិល្បៈ)

**ប្រជុំលើកទី២ (១៨ កក្កដា ២០២៤)**

**<u>ពាក្យស្លោក</u>**

- ការជួញដូរមនុស្សជាអំពើខុសច្បាប់ដែលទទួលទោសចាប់ពី ១៥ឆ្នាំ ដល់ ២៥ឆ្នាំ (តំណាងក្រសួងការងារ)
- ការផ្តល់សេវាជ្រើសរើសពលករធ្វើការក្រៅប្រទេសខុសច្បាប់ គឺជាអំពើជួញដូរមនុស្ស (តំណាងក្រសួងការងារ)
- តួនាទីសាសនាក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស(តំណាងព្រះពុទ្ធសាសនា)
- តួនាទីសាសនាក្នុងការលើកតម្លៃមនុស្ស (តំណាងព្រះពុទ្ធសាសនា)
- មនុស្សជាតិមានតម្លៃបំផុតក្នុងការការពារ (តំណាងព្រះពុទ្ធសាសនា)
- តំណាងគ្រីស្តបរិស័ទកម្ពុជាសំណូមពរបញ្ចូលសារទាំងបីរបស់តំណាងព្រះពុទ្ធសាសនា មកតែមួយឃ្លា ដែលបង្ហាញន័យការចូលរួមសាសនាទាំងអស់ និងសីលធម៌សង្គម
- យើងនាំគ្នាទប់ស្កាត់ល្បិចកលជនខិលខូចក្នុងអំពើជួញដូរមនុស្ស (តំណាងក្រសួងអប់រំ)
- ស្ត្រី បុរស និងកុមារ ជាធនធានមានតម្លៃរបស់ជាតិ សូមចូលរួមថែរក្សាការពារកុំឱ្យក្លាយជាកម្មវត្ថុការជួញដូរ (តំណាងក្រសួងអប់រំ)
- ផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរដល់ជនទាំងឡាយណាដែលជាមេក្លោង អ្នកសមគំនិត អ្នកផ្តល់មធ្យោបាយជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ(តំណាងក្រសួងអប់រំ)
- រួមគិត រួមធ្វើ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស (ក្រសួងកិច្ចការនារី)
- គ្រួសារខ្ញុំមិនមានអំពើជួញដូរមនុស្ស ចុះគ្រួសារអ្នកវិញ? (ឯកឧត្តម អ៊ូ ម៉ានីវ៉ា)
- កុំជឿការឃោសនា អូសទាញ ដោយគ្មានការពិចារណា ងាយរងគ្រោះដោយអំពើជួញដូរមនុស្ស (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)
- លើកកម្ពស់សីលធម៌សង្គម អប់រំមនុស្សឱ្យរួចពីការជួញដូរមនុស្ស (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)

**<u>ប្រធានបទ</u>**

- ការពង្រឹងជំនឿសាសនាទប់ស្កាត់អំពើជួញដូរមនុស្ស (តំណាងសាសនាឥស្លាម)
- អំពើជួញដូរមនុស្ស ជាអំពើបាបក្នុងសាសនា (តំណាងសាសនាឥស្លាម)
- អន្តរសាសនាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សតាមរយៈការពពោះជំនួស(តំណាងសាសនាគ្រឹស្ត)
- អន្តរសាសនាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សតាមរយៈការពង្រឹងតួនាទីព្រះធម៌ (តំណាងសាសនាគ្រឹស្ត)
- គ្រប់សាសនាចូលរួមជ្រោងទង់ទប់ស្កាត់អំពើជួញដូរមនុស្ស (ក្រសួងព័ត៌មាន)
- មនុស្សមានគុណធម៌ (ក្រសួងកិច្ចការនារី)